ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**របាយការណ៍**
**ស្តីពី**
**លទ្ធផលនៃការពិនិត្យការអនុវត្តចំណូលថវិកា ប្រចាំត្រីមាសទី២ ឆ្នាំ២០២២**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

## I-ច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២

យោងតាមព្រះរាជក្រមលេខ នស/រកម/១២២១/០១៩ ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២១ បានប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២។ នៅក្នុងច្បាប់នេះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានគ្រោងចំណូលឆ្នាំ២០២២ សរុបមានចំនួន ៣៧ ១៤៤,៨ លានរៀល ក្នុងនោះ ៖

(ក) **រដ្ឋបាលកណ្តាល**៖ បានគ្រោងចំណូលសរុបចំនួន ៣៧ ១៤៣,៤ លានរៀល ចំណូលនេះរួមមាន :

(១)ផលទុននៃទ្រព្យសម្បត្តិរដ្ឋមានចំនួន២០ ៩៩២ លានរៀល ស្មើនឹង១០០% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ (២) ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិនិងសេវាមានចំនួន ១២ ៨៣១,៤ លានរៀល ស្មើនឹង១១៥% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២១(៣) ផលពីការផាកពិន័យនិងការដាក់ទណ្ឌកម្ម មានចំនួន៣ ៣២០ លានរៀល ស្មើនឹង១០១,៥% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ។

(ខ) **មន្ទីររាជធានី ខេត្ត**៖ បានគ្រោងចំណូលសរុបចំនួន១,៤ លានរៀល ស្មើនឹង ១០០% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២១ចំណូលនេះបានពីការជួលដីទំនេរនៃផលទុនពីការលក់ជួលទ្រព្យសម្បត្តិនិងសេវារបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ស្ពឺ។

## II-លទ្ធផលសម្រេចបាន

ដោយអនុវត្តតាមច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ នៅក្នុងត្រីមាសទី២ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អនុវត្តប្រមូលចំណូល សរុបមានចំនួន ១២ ១៧៦,៤លានរៀល ស្មើនឹង៥៩,២% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង១៤៥,៩%ធៀបនឹងកម្មវិធីដែលបានដាក់ចេញក្នុងនោះ ៖

(ក) **រដ្ឋបាលកណ្តាល**៖ អនុវត្តប្រមូលចំណូល សរុបមានចំនួន១២ ១៧៦,៤លានរៀល ស្មើនឹង៥៩,២% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ឬស្មើនឹង១៤៥,៩%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ ចំណូលនេះរួមមាន(១)ផលទុននៃទ្រព្យសម្បត្តិរដ្ឋមានចំនួន ៧ ៥២៥,៨ លានរៀល ស្មើនឹង៥២,៣% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង៣០០,៥%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (២) ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិនិងសេវាមានចំនួន ៤ ០៩៥,៨ លានរៀល ស្មើនឹង៧៦% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង៨៨,៧ %ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (៣) ផលពីការផាកពិន័យនិងការដាក់ទណ្ឌកម្ម មានចំនួន៥៤៣,៤ លានរៀល ស្មើនឹង៣៤,១% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង៤៤,៤% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ(៤)ផលហិរញ្ញវត្ថុ មានចំនួន ១១,៤លានរៀល ដែលជាចំណូលបានមកពីការបង់សំណោសចំណាយប្រាក់បៀវត្ស។



អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
N° 200 Preah Norodom Blvd, Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ: (៨៥៥) ២៣-២១៧ ៣២០
Phone: (023) 726 128 / 726 129, Fax: (855) 23-217 320

(ខ) មន្ទីររាជធានី ខេត្ត ៖

នៅក្នុងត្រីមាសទី២នេះមន្ទីរមិនទាន់បានអនុវត្តចំណូលពីថ្លៃឈ្នួលដីនៅឡើយ។

ជារួមការអនុវត្តចំណូល របស់រដ្ឋបាលកណ្តាលសម្រេចបានល្អស្របទៅតាមកម្មវិធីដែលបានដាក់ចេញ ម្យ៉ាងទៀត ដោយពិនិត្យទៅតាមប្រភេទចំណូលនីមួយៗឃើញថាមានភាពរលូនធៀបនឹងកម្មវិធីដែលបានដាក់ចេញដូចជា៖

(១) ផលទុននៃទ្រព្យសម្បត្តិរដ្ឋអនុវត្តបានខ្ពស់៣០០,៥% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ ករណីនេះបណ្តាល មកពីចំណូលផលពីព្រៃឈើអនុវត្តបាន៤៨,២%ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង២៦០,៨%ធៀបនឹងកម្មវិធីដែល បានដាក់ចេញ និងចំណូលពីសម្បទានដីសេដ្ឋកិច្ចអនុវត្តបាន៥៥,៧% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង៣២៩,៧% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ។

(២)ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិនិងសេវា អនុវត្តបានល្អគឺដោយសារចំណូលពីការលក់ផលិតផលកសិកម្ម អនុវត្តបាន៨៦,៣% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង២៤០០%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ ។ ចំណូលពីការ អនុញ្ញាតរដ្ឋបាល ទម្រង់ការរដ្ឋបាលនិងការគ្រប់គ្រងរដ្ឋបាលផ្សេងៗ អនុវត្តបាន ៥៨,១%នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង ១២៨,៤ធៀបនឹងកម្មវិធីដែលបានដាក់ចេញ។ ចំពោះការជួលទ្រព្យសម្បត្តិរដ្ឋដូចជាការជួលដីទំនេរ និងដីមានអគារអនុវត្តបាន ៥៦,៦%នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង៧៨,១%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ។ ដោយឡែកចំណូលផលពីការ គ្រប់គ្រងរដ្ឋបាលដែលបានពីការត្រួតពិនិត្យអនាម័យសត្វ និងការត្រួតពិនិត្យគុណភាពផលិតផល អនុវត្តបាន៨១,១%នៃច្បាប់ ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង៨៥,៧%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ។

(៣) ចំណូលពីការផាកពិន័យនិងដាក់ទណ្ឌកម្មអនុវត្តបាន៣៤,១%នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង៤៤,៤% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ។ លទ្ធផលនេះបានមកដោយសារការផាកពិន័យលើផលិតផលសាច់សត្វ និងការដឹក ជញ្ជូនសត្វរបស់អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ អនុវត្តបាន១១៦,៧ % នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង ១០០%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ ការពិន័យលើការនេសាទខុសច្បាប់ អនុវត្តបាន២៤៧%នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២២ ឬស្មើនឹង១០០%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ និងការពិន័យលើបទល្មើសព្រៃឈើ អនុវត្តបាន៤២,៨ %នៃ ច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង៩៩,៨%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ ការពិន័យតាមសាលក្រមតុលាការអនុវត្ត បាន៦៦,៥%នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង៩៩,៩%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ ការពិន័យលើបទល្មើស ជី-ថ្នាំកសិកម្ម អនុវត្តបាន៨,៨%នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង៨០%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ។

## III-**ទិសដៅអនុវត្តបន្ត**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បន្តខិតខំនិងជំរុញការប្រមូលចំណូលបង់ចូលថវិកាជាតិស្របទៅតាម កម្មវិធីចំណូលប្រចាំត្រីមាសទី៣ឆ្នាំ២០២២ ដែលមានទឹកប្រាក់សរុបចំនួន៨ ៨១៥ ៧០០ ០០០រៀល។ កិច្ចការបន្ទាន់មួយ ទៀតដែលក្រសួងត្រូវអនុវត្ត គឺបន្តរៀបចំឯកសារកែសម្រួលកម្រងសេវាសាធារណៈនិងសេចក្តីព្រាងប្រកាសអន្តរក្រសួង ដាក់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## IV-**សេចក្តីសន្និដ្ឋាន**

សរុបសេចក្តីមក ការអនុវត្តប្រមូលចំណូលប្រចាំត្រីមាសទី២ របស់រដ្ឋបាលកណ្តាលសម្រេចបានលទ្ធផលល្អប្រសើរ គឺលើសផែនការធៀបនឹងកម្មវិធីដែលបានដាក់ចេញទាំងផ្នែកចំណូលពីសេវាសាធារណៈ និងការជួលដីធ្លី និងដីសម្បទាន សេដ្ឋកិច្ច ។ទន្ទឹមនេះចំណូលពីការជួលដីធ្លីមានអគាររបស់អគ្គនាយកដ្ឋានកៅស៊ូ អនុវត្តបានទាប ម្យ៉ាងទៀតចំណូលពីការ ជួលដីមានអគាររបស់អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វនិងចំណូលពីថ្លៃឈ្នួល ដីទំនេររបស់មន្ទីរកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ ខេត្តកំពង់ស្ពឺមិនទាន់បានអនុវត្តបង់នៅឡើយ។

ដូច្នេះដើម្បីអនុវត្តប្រមូលចំណូលឲ្យបានតាមផែនការឆ្នាំ២០២២ អង្គភាពពាក់ព័ន្ធទទួលបន្ទុកប្រមូលចំណូលត្រូវបន្តការយកចិត្តទុកដាក់ក្នុងការប្រមូល និងបង់ចំណូលចូលថវិការដ្ឋឲ្យបានទាន់ពេលវេលា ស្របតាមគោលការណ៍ និងនីតិវិធីថ្មីៗពាក់ព័ន្ធការបង់ចំណូលរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ថ្ងៃសុក្រ ២រោច ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០២២

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**អនុរដ្ឋលេខាធិការ**

**ឃី កុសល**